FEED THE FUTURE
The U.S. Government's Global Hunger & Food Security Initiative

# ប្រៀបធៀបមេចំណី កាកសណ្តែកសៀង និងបាស្មិចបន្ថែមលើកន្ទក់ដែលជាចំណីគ្រឹះលើការលូតលាស់របស់ជ្រូក

ស្រេង សាម៉ន[១] J. M. DeRouchey[៣] កែវ សាធ[២] M.D.Tokach[៣] J.L.Vipham[៣] តៃ គុយហោ[១]

[*១] មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

[២] មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

[៣] ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសត្វ និងឧស្សាហកម្ម សាកលវិទ្យាល័យរដ្ឋកាន់សាស់ សហរដ្ឋអាមេរិក

## សេចក្តីផ្តើម

នៅប្រទេសកម្ពុជា កន្ទក់ត្រូវបានស្គាល់ថាជាវត្ថុធាតុដើមសាមញ្ញបំផុតសម្រាប់ផ្តល់ជារបបចំណីជ្រូកប្រចាំថ្ងៃ។ ប៉ុន្តែកន្ទក់ដែលកសិកររកបានពីរោងម៉ាស៊ីនស្រូវខ្នាតតូចក្នុងតំបន់ជាទូទៅមានគុណភាពទាប ដែលមានកម្រិតប្រូតេអ៊ីនពី៨ - ១០ ភាគរយ ជាមួយនឹងបរិមាណយ៉ាងច្រើននៃអង្កាមដែលធ្វើឲ្យគុណភាពកន្ទក់ថយចុះ ក្នុងនោះកន្ទក់ដែលមានគុណភាពខ្ពស់មានប្រូតេអ៊ីនពី១២ ទៅ ១៣ ភាគរយ (Samkol P., K. Borin and S. Sovann, 2006)។ បើទោះបីជាកសិករចិញ្ចឹមជ្រូកខ្នាតតូចជារឿយៗផ្តល់កន្ទក់ជាចំណីជ្រូក ប៉ុន្តែដើម្បីផ្តល់ឲ្យគ្រប់នៅតម្រូវការសារធាតុចិញ្ចឹមក្នុងរបបចំណីអាហារ ត្រូវមានបន្ថែមកម្រិតប្រូតេអ៊ីន សារធាតុខនិជ និងវីតាមីនចាំបាច់ ដែលត្រូវលាយជាមួយកន្ទក់សម្រាប់ផ្តល់ឲ្យជ្រូកផងដែរ។ ដោយពេលថ្មីៗនេះ មេចំណីជ្រូកដែលមានប្រូតេអ៊ីនខ្ពស់បានរួមបញ្ចូលស្រាប់ជាមួយសារធាតុខនិជ និងវីតាមីន គឺមានតម្លៃថ្លៃ ហើយគុណភាពរបស់វាមិនបានដឹងច្បាស់ផងដែរ។ ក្នុងនោះកាកសណ្តែកសៀងជាប្រភពប្រូតេអ៊ីនដែលមានគុណភាពខ្ពស់ ហើយប្រភពប្រូតេអ៊ីននៃកាកសណ្តែកសៀងទាំងនេះបានត្រូវប្រើប្រាស់យ៉ាងទូលាយសម្រាប់ជាចំណីជ្រូក(នៅទូទាំងពិភពលោក (Stein H. H . et al., 2016, FAO, 2008)។ ដូចគ្នានេះដែរ បាស្មិច (Base mix) ដែលជាការរួមបញ្ចូលគ្នានៃម៉ាក្រូសារធាតុខនិជ (Macro minerals) និងមីក្រូសារធាតុខនិជ (Trace minerals) ពពួកវីតាមីន ព្រមទាំងមានផ្ទុកនៅអាមីណូអាស៊ីសំយោគសំខាន់ៗមួយចំនួន ដែលជាសក្តានុពលប្រើប្រាស់មួយសម្រាប់កសិករចិញ្ចឹមជ្រូកខ្នាតតូច។ គោលបំណងនៃការសិក្សានេះគឺធ្វើការវាយតម្លៃទៅលើការជំនួស មេចំណីជ្រូកជាមួយនឹងបាស្មិច រួមទាំងកាកសណ្តែកសៀង លើចំណីគ្រឹះកន្ទក់លើការលូតលាស់របស់ជ្រូកសាច់។

## សម្ភារ និងវិធីសាស្ត្រស្រាវជ្រាវ

ការពិសោធនេះត្រូវបានធ្វើឡើងនៅ ភូមិព្រៃកតាព្រីង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល ដែលមានរយៈពេល ៤២ ថ្ងៃ ចាប់ផ្តើមនៅចុងខែមិថុនា រហូតដល់ដើមខែសីហា ឆ្នាំ ២០១៨។ ជ្រូកពិសោធន៍សរុប ៦០ក្បាល ជាជ្រូកឈ្មោល (ពូជយ៉កសៀរ x ឌុយរ៉ក់) និងមានទម្ងន់មធ្យមពិសោធន៍ ៥៦,៤៩ គីឡូក្រាម។ ទ្រុងត្រូវបានបែងចែកជា ១៥កូនទ្រុង ដែលកូនទ្រុងនីមួយៗ មានទំហំ ២ x ៣ម៉ែត្រ ការពិសោធនេះធ្វើតាមគំរូប្លង់ CRD។

**ចំណីពិសោធន៍ត្រូវបានបែងចែកជា ៤ក្រុម៖**

ក្រុមទី១៖ កន្ទក់ ៨០% + មេចំណី ២០%

ក្រុមទី២៖ កន្ទក់ ៩៥% + មេចំណី ៥%

ក្រុមទី៣៖ កន្ទក់ ៩៧,៥% + បាស្មិច ២,៥%

ក្រុមទី៤៖ កន្ទក់ ៩២,៥% + បាស្មិច ២,៥% + កាកសណ្តែកសៀង ៥%

តារាងទី១ តម្លៃសារធាតុចិញ្ចឹមក្នុងវត្ថុធាតុដើមផ្សំចំណី (គិតក្នុងម៉ាស់ស្ងួត)

| វត្ថុធាតុដើម/ប៉ារ៉ាម៉ែត្រ | ម៉ាស់ស្ងួត DM (%) | ប្រូតេអ៊ីន CP (%) | ជាតិសរសៃ CF (%) | ខ្លាញ់ EE (%) | ផេះ Ash (%) | ADF (%) | NDF (%) |
|---|---|---|---|---|---|---|---|
| កន្ទក់ | 90.51 | 11.81 | 10.96 | 12.23 | 8.92 | 16.85 | 20.65 |
| កាកសណ្តែកសៀង | 89.18 | 50.45 | 3.41 | 1.19 | 7.87 | 6.84 | 7.32 |
| មេចំណីជ្រូក | 93.1 | 46.43 | 3.67 | 4.44 | 18.06 | 6.84 | 16.68 |

តារាងទី២ តម្លៃសារធាតុចិញ្ចឹមក្នុងចំណីពិសោធន៍ (គិតក្នុងម៉ាស់ស្ងួត)

| ចំណីពិសោធន៍/ប៉ារ៉ាម៉ែត្រ | ម៉ាស់ស្ងួត DM (%) | ប្រូតេអ៊ីន CP (%) | ជាតិសរសៃ CF (%) | ខ្លាញ់ EE (%) | ផេះ Ash (%) | ADF (%) | NDF (%) |
|---|---|---|---|---|---|---|---|
| កន្ទក់ ៨០%+មេចំណី ២០% | 90.07 | 19.00 | 11.00 | 9.78 | 10.61 | 15.61 | 24.31 |
| កន្ទក់ ៩៥%+មេចំណី ៥% | 89.07 | 13.54 | 11.84 | 8.68 | 9.08 | 17.03 | 22.88 |
| កន្ទក់៩៧,៥%+បាស្មិច ២,៥% | 89.50 | 12.17 | 11.61 | 10.34 | 10.87 | 20.63 | 23.40 |
| កន្ទក់ ៩២,៥%+បាស្មិច ២,៥%+កាកស.ស៥% | 89.38 | 13.62 | 10.42 | 10.34 | 10.04 | 15.09 | 21.08 |

**ការប្រមូលទិន្នន័យ៖**

ការផ្តល់ចំណីប្រចាំថ្ងៃបានធ្វើឡើង ៣ដង/ថ្ងៃ ចំណែកចំណីនៅសល់ត្រូវបានថ្លឹងហើយកត់ត្រារៀងរាល់ថ្ងៃ។ រីឯការថ្លឹងទម្ងន់ជ្រូកប្រចាំសប្តាហ៍ នៅដំណាក់កាលពិសោធន៍នេះបានធ្វើឡើងនៅពេលចាប់ផ្តើម ៧ថ្ងៃ ២១ និង៤២ថ្ងៃ រាល់ការថ្លឹងធ្វើឡើងមុនពេលការផ្តល់ចំណីថ្មី។ ការប្រមូលសីតុណ្ហភាពធ្វើឡើងនៅពេលព្រឹកម៉ោង ៧:០០ ពេលថ្ងៃម៉ោង ១២:០០ និងពេលល្ងាចម៉ោង ៦:០០ ជារៀងរាល់ថ្ងៃជាមួយនឹងសំណើមបរិយាកាសក្នុងទ្រុងពិសោធន៍ផងដែរ។



កាកសណ្តែកសៀង មេចំណី និងបាស្មិច


កន្ទក់


ការលាយចំណីជ្រូក


ការរៀបចំបែងចែកចំណីជ្រូក


ការសម្អាតទ្រុងមុនពេលផ្តល់ចំណី


ការថ្លឹងទម្ងន់ និងប្រមូលទិន្នន័យជ្រូក

## លទ្ធផលពិសោធន៍
















## សន្និដ្ឋាន

ការផ្តល់ចំណីជ្រូកដែលមានកន្ទក់ កាកសណ្តែកសៀង និងបាស្មិច (Base mix) បានធ្វើឲ្យជ្រូកមានការលូតលាស់ល្អប្រសើរ និងបានបង្កើនផលចំណេញត្រលប់មកវិញប្រហាក់ប្រហែលគ្នាបើប្រៀបធៀបជាមួយការផ្តល់ចំណីជ្រូកដែលមានកន្ទក់លាយមេចំណីដែលមានប្រូតេអ៊ីនខ្ពស់។ ការប្រើប្រាស់កាកសណ្តែកសៀង និងបាស្មិចបានផ្តល់ឲ្យនូវឱកាសដល់កសិករចិញ្ចឹមជ្រូកទទួលបានផលចំណេញសេដ្ឋកិច្ចត្រលប់មកវិញ។

## ឯកសារយោង

FAO, 2008. Swine Marketing in Cambodia: Reducing market distortion, Improving Competitiveness and Ensuring Safe Trade, pp 8

Samkol P., K. Borin and S. Sovann, 2006. Pig system in Southeast Asia– The case of Cambodia.. Uploaded by Khieu Borin on 05 June 2014. https://www.researchgate.net/publication/262840137

Stein, H.H., Lagos, L.V., Casas, G.A., 2016. Nutritional value of feed ingredients of plant origin fed to pigs. Animal Feed Science and Technology. http://dx.doi.org/10.1016/j.anifeedsci.2016.05.003

USAID FROM THE AMERICAN PEOPLE · KANSAS STATE UNIVERSITY · HORTICULTURE INNOVATION LAB · UC DAVIS UNIVERSITY OF CALIFORNIA · ILRI INTERNATIONAL LIVESTOCK RESEARCH INSTITUTE · CGIAR · UF IFAS UNIVERSITY of FLORIDA